គណិតវិទ្យា

កម្រិតវិទ្យាល័យ

ធរណីមាត្រ

សំរាប់ការប្រលងសិស្សពូកែ និង ប្រលងប្រជែងនានា



-ទ្រឹស្តី
-ឧទាហរណ៍
-វិធីសាស្ត្រដោះស្រាយ
-លំហាត់
-ដំណោះស្រាយ

រៀបរៀងដោយ ហេង សុខា

គណិតវិទ្យា

ធរណីមាត្រ

សំរាប់ការប្រលងសិស្សពូកែ និង ប្រលងប្រជែងនានា

រៀបរៀងដោយ ហេង សុខា

សហការណ៏ដោយ

ឈួរ គឹមហុី

ង៉ូវ ម៉េងតាំង

មាតិកា

ជំពូក ១ សង្ខេបរូបមន្តសំខាន់ៗ

១. ទំនាក់ទំនងក្នុងត្រីកោណ

និមិត្តសញ្ញាដែលប្រើ:

a, b, c	: រង្វាស់ជ្រុងដែលឈមមុំ A, B, C នៃ ΔABC
S	: ក្រលាផ្ទៃត្រីកោណ
p	: កន្លះបរិមាត្រនៃត្រីកោណ
h_a, h_b, h_c	: ប្រវែងកំពស់គូសចេញពីកំពូល A, B, C
l_a, l_b, l_c	: ប្រវែងកន្លះបន្ទាត់ពុះមុំក្នុង
m_a, m_b, m_c	: ប្រវែងមេដ្យានគូសចេញពីកំពូលទាំងបី
r_a, r_b, r_c	: ប្រវែងកាំរង្វង់
R	: ប្រវែងកាំរង្វង់ចារឹកក្រៅត្រីកោណ ABC
r	: កាំរង្វង់ចារឹកក្នុង ΔABC

១.ទ្រឹស្តីបទស៊ីនីស:

$$\frac{a}{\sin A} = \frac{b}{\sin B} = \frac{c}{\sin C} = 2R$$

២. ទ្រឹស្តីបទកូស៊ីនីស:

$$a^2 = b^2 + c^2 - 2bc\cos A$$
$$b^2 = a^2 + c^2 - 2ac\cos B$$
$$c^2 = a^2 + b^2 - 2ab\cos C$$

៣. ទ្រឹស្តីបទចំនោល:

$$a = b\cos C + c\cos B$$
$$b = c\cos A + a\cos C$$
$$c = a\cos B + b\cos A$$

៤. រូបមន្តក្រលាផ្ទៃ:

$$S = \frac{1}{2}ah_a = \frac{1}{2}bh_b = \frac{1}{2}ch_c$$
$$= \sqrt{p(p-a)(p-b)(p-c)}$$
$$= \frac{1}{2}bc\sin A = \frac{1}{2}ac\sin B = \frac{1}{2}ab\sin C$$
$$= \frac{abc}{4R} = pr = (p-a)r_a = (p-b)r_b = (p-c)r_c$$
$$= 2R^2\sin A.\sin B.\sin C$$

៥. រូបមន្តកាំចារឹកក្នុង:

$$r = \frac{a\sin\frac{B}{2}\sin\frac{C}{2}}{\cos\frac{A}{2}} = \frac{b\sin\frac{A}{2}\sin\frac{C}{2}}{\cos\frac{B}{2}} = \frac{c\sin\frac{A}{2}\sin\frac{B}{2}}{\cos\frac{C}{2}}$$
$$= (p-a)\tan\frac{A}{2} = (p-b)\tan\frac{B}{2} = (p-c)\tan\frac{C}{2}$$

$$r_a = p\tan\frac{A}{2} = \frac{a\cos\frac{B}{2}\cos\frac{C}{2}}{\cos\frac{A}{2}}$$

$$r_b = p\tan\frac{B}{2} = \frac{b\cos\frac{A}{2}\cos\frac{C}{2}}{\cos\frac{B}{2}}$$

$$r_c = p\tan\frac{C}{2} = \frac{c\cos\frac{B}{2}\cos\frac{A}{2}}{\cos\frac{C}{2}}$$

៦. រូបមន្តកន្លះបន្ទាត់ពុះមុំក្នុង:

$$l_a = \frac{2bc\sin\frac{A}{2}}{b+c} = \frac{2}{a+c}\sqrt{pbc(p-a)}$$

$$l_b = \frac{2ac\cos\frac{B}{2}}{a+c} = \frac{2}{a+c}\sqrt{pac(p-b)}$$

$$l_c = \frac{2ab\cos\frac{C}{2}}{a+b} = \frac{2}{a+b}\sqrt{pab(p-c)}$$

៧. រូបមន្តមេដ្យាន:

$$4{m_a}^2 = 2b^2 + 2c^2 - a^2 = b^2 + c^2 + 2bc\cos A$$

$$4{m_b}^2 = 2c^2 + 2a^2 - b^2 = c^2 + a^2 + 2ca\cos B$$

$$4{m_c}^2 = 2a^2 + 2b^2 - c^2 = a^2 + b^2 + 2ab\cos C$$

២. វិសមភាព

១. វិសមភាព Cauchy:

1. $\forall\ a, b \in R^{+}$ គេបាន $a+b \geq 2\sqrt{ab}$ ។

   សមភាពកើតឡើងកាលណា $a=b$ ។

2. ជាទូទៅ $\forall a_i \in R\,(i=1,2,3.......,n)$ គេបាន :

$$a_1+a_2+a_3+....+a_n \geq n\sqrt{a_1a_2a_3....a_n}$$

   សមភាពកើតឡើងកាលណា $a_1=a_2=a_3=.......=a_n$ ។

២. វិសមភាព Bernoulli:

1. $\forall x>-1,\ n\in N^{*}$ គេបាន: $(1+x)^n \geq 1+nx$ ។

   សមភាពកើតឡើងកាលណា $x=0$ រឺ $n=1$ ។

2. $\forall x>-1,\ r\in Q,\ r\geq 1$ គេបាន $(1+x)^r \geq 1+rx$ ។

   សមភាពកើតឡើងកាលណា $x=0$ រឺ $r=1$ ។

3. $\forall x>-1,\ r\in Q,\ 1\leq r\leq 1$ គេបាន $(1+x)^r \leq 1+rx$ ។

   សមភាពកើតឡើងកាលណា $x=0$ រឺ $r=1$ ។

៣. វិសមភាព Bunyakovsky:

1. $\forall a,b,c,d\in R$ គេបាន: $|ac+bd| \leq \sqrt{(a^2+b^2)(c^2+d^2)}$

   រឺ $(ac+bd)^2 \leq (a^2+b^2)(c^2+d^2)$

   សមភាពកើតឡើងកាលណា $\frac{a}{b}=\frac{c}{d}$ ។

2. $\forall a_i, b_i \in R\,(i=1,2,3,....,n)$ គេបាន៖

$$(a_1b_1+a_2b_2+....+a_nb_n)^2 \le (a_1^2+a_2^2+....+a_n^2)(b_1^2+b_2^2+....+b_n^2)$$

សមភាពកើតឡើងកាលណា $\dfrac{a_1}{b_1}=\dfrac{a_2}{b_2}=....=\dfrac{a_n}{b_n}$ ។

៤. វិសមភាព Minkowski:

1. $\forall a,b,c,d \in R$ គេបាន៖ $\sqrt{(a+c)^2+(b+d)^2} \le \sqrt{a^2+b^2}+\sqrt{c^2+d^2}$ ។

សមភាពកើតឡើងកាលណា $\dfrac{a}{b}=\dfrac{c}{d}$ ។

2. $\forall a_i, b_i \in R\,(i=1,2,3,....,n)$ គេបាន៖

$$\sqrt{(a_1+a_2+...+a_n)^2+(b_1+b_2+...+b_n)^2}$$
$$\le \sqrt{a_1^2+b_2^2}+\sqrt{a_2^2+b_2^2}+...+\sqrt{a_n^2+b_n^2}$$

សមភាពកើតឡើងកាលណា $\dfrac{a_1}{b_1}=\dfrac{a_2}{b_2}=....=\dfrac{a_n}{b_n}$ ។

៥. វិសមភាពត្រីកោណ៖

បើ a, b, c ជារង្វាស់ជ្រុងនៃត្រីកោណ គេបានវិសមភាព៖

1. $|b-c|<a<b+c$

2. $|a-c|<b<a+c$

3. $|a-b|<c<a+b$

៣. អនុគមន៍ត្រីកោណមាត្រ

១. ទំនាក់ទំនងសំខាន់ៗ:

1. $\sin^2\alpha + \cos^2\alpha = 1$

2. $\tan^2\alpha + 1 = \dfrac{1}{\cos^2\alpha} \quad (\cos\alpha \neq 0)$

3. $\cot^2\alpha + 1 = \dfrac{1}{\sin^2\alpha} \quad (\cos\alpha \neq 0)$

២. រូបមន្តផលបូក និង ផលដក:

1. $\cos(a-b) = \cos a\cos b + \sin a\sin b$

2. $\cos(a+b) = \cos a\cos b - \sin a\sin b$

3. $\sin(a+b) = \sin a\cos b + \sin b\cos a$

4. $\sin(a-b) = \sin a\cos b - \sin b\cos a$

5. $\tan(a+b) = \dfrac{\tan a + \tan b}{1-\tan a\tan b} \quad \left(a,\ b,\ (a+b) \neq \dfrac{\pi}{2} + k\pi\right)$

6. $\tan(a-b) = \dfrac{\tan a - \tan b}{1+\tan a\tan b} \quad \left(a,\ b,\ (a-b) \neq \dfrac{\pi}{2} + k\pi\right)$

៣. រូបមន្តមុំ 2α និង 3α :

1. $\sin 2\alpha = 2\sin\alpha\cos\alpha$

2. $\cos 2\alpha = 2\cos^2\alpha - 1$

3. $\cos 2\alpha = 1 - 2\sin^2\alpha$

4. $\cos 2\alpha = \cos^2 - \sin^2\alpha$

5. $\tan 2\alpha = \dfrac{2\tan\alpha}{1-\tan^2\alpha}$

6. $\cot 2\alpha = \dfrac{\cot^2\alpha - 1}{2\cot\alpha}$

7. $\cos 3\alpha = 4\cos^3\alpha - 3\cos\alpha$

8. $\sin 3\alpha = 3\sin\alpha - 4\sin^3\alpha$

9. $\tan 3\alpha = \dfrac{3\tan\alpha - \tan^3\alpha}{1-3\tan^2\alpha}$

10. $\cot 3\alpha = \dfrac{\cot^3\alpha - 3\cot\alpha}{3\cot^2\alpha - 1}$

៤. រូបមន្តកន្លះមុំ:

1. $\sin\dfrac{\alpha}{2} = \pm\sqrt{\dfrac{1-\cos\alpha}{2}}$

2. $\cos\dfrac{\alpha}{2} = \pm\sqrt{\dfrac{1+\cos\alpha}{2}}$

3. $\tan\dfrac{\alpha}{2} = \pm\sqrt{\dfrac{1-\cos\alpha}{1+\cos\alpha}}$

4. $\tan\dfrac{\alpha}{2} = \dfrac{\sin\alpha}{1+\cos\alpha}$

៥. គណនា $\sin\alpha, \cos\alpha, \tan\alpha$ ជាអនុគមន៍ t $(t = \tan\dfrac{\alpha}{2})$

$$\sin\alpha = \frac{2t}{1+t^2}, \quad \cos\alpha = \frac{1-t^2}{1+t^2}, \quad \tan\alpha = \frac{2t}{1-t^2}$$

៦. រូបមន្តបំលែង:

៦.១ បំលែងពីផលគុណទៅផលបូក

1. $\cos a \cos b = \dfrac{1}{2}\left[\cos(a+b) + \cos(a-b)\right]$

2. $\sin a \sin b = \dfrac{1}{2}\left[\cos(a-b) - \cos(a+b)\right]$

3. $\sin a \cos b = \frac{1}{2}[\sin(a+b)+\sin(a-b)]$

4. $\sin b \sin a = \frac{1}{2}[\sin(a+b)-\sin(a-b)]$

៦.២ បំលែងពីផលបូកទៅផលគុណ

1. $\cos p + \cos q = 2\cos\frac{p+q}{2}\cos\frac{p-q}{2}$

2. $\cos p - \cos q = -2\sin\frac{p+q}{2}\sin\frac{p-q}{2}$

3. $\sin p + \sin q = 2\sin\frac{p+q}{2}\cos\frac{p-q}{2}$

4. $\sin p - \sin q = 2\sin\frac{p-q}{2}\cos\frac{p+q}{2}$

5. $\tan p + \tan q = \frac{\sin(p+q)}{\cos p \cos q}$

6. $\tan p - \tan q = \frac{\sin(p-q)}{\cos p \cos q}$

7. $\cot p + \cot q = \frac{\sin(p+q)}{\sin p \sin q}$

8. $\cot p - \cot q = \frac{\sin(q-p)}{\sin p \sin q}$

៤.បណ្តាទ្រឹស្តីបទផ្សេងទៀត

១. ទ្រឹស្តីបទអង្កត់ធ្នូប្រសព្វគ្នា:

បើអង្កត់ធ្នូ AB & CD នៃរង្វង់ប្រសព្វគ្នាត្រង់ X នោះ



$$AX.XB = CX.XD$$

២. ទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំ

បើ AX ជាកន្លះបន្ទាត់ពុះ $\angle A$ នៃ ΔABC គេបាន:



$$\frac{BX}{XC} = \frac{AB}{AC}$$

៣. ទ្រឹស្តីបទ Ptolémé

បើ ABCD ជាចតុកោណចារឹកក្នុងរង្វង់ និង មាន AC & CD ជាអង្កត់ទ្រូង គេបាន:



$$CD.AB + BC.AD = AC.BD$$

៤. ទ្រឹស្តីបទ Céva:

បើ X, Y, Z ជាចំនុចនៅលើជ្រុង BC, AC , AB នៃ ΔABC ដែល AX, BY, &

CZ ប្រសព្វគ្នាត្រង់ចំនុចតែមួយ គេបានៈ



$$\frac{AZ}{ZB}.\frac{BX}{XC}.\frac{CY}{YA}=1$$

(បំនកស្រាយនៅលំហាត់លេខ ៦៦)

៥. ទ្រឹស្តីបទ Simson:

គេអោយ P ជាចំនុចនៅលើរង្វង់ចារឹកក្រៅ ΔABC និង E

F, G ជាជើងចំនោលកែងពី P ទៅលើជ្រុងទាំង3នៃ ΔABC

គេបានៈ E, F, G រត់ត្រង់គ្នា ។



(បំនកស្រាយនៅលំហាត់លេខ ៦៧)

ជំពូក ២ **លំហាត់**

១. បណ្តាលំហាត់ទាក់ទងនឹងរូបមន្តទំនាក់ទំនងក្នុងត្រីកោណ

០១. បង្ហាញថាក្រលាផ្ទៃ ΔABC ផ្ទៀងផ្ទាត់ $S=\frac{1}{4}(a^2\sin 2B+b^2\sin 2A)$ ។

០២. តាង R ជាកាំរង្វង់ចារឹកក្រៅ ΔABC ។ ស្រាយថា:

$$\cot A+\cot B+\cot C=\frac{R(a^2+b^2+c^2)}{abc}$$

០៣. ក្នុង ΔABC, AM ជាមេដ្យាន ហើយ $A\hat{M}B=\alpha$ ។ ស្រាយថា $\cot\alpha=\frac{\sin(B-C)}{2\sin B\sin C}$ ។

០៤. ក្នុង ΔABC, CM ជាមេដ្យាន ហើយ $A\hat{C}M=\alpha; B\hat{C}M=\beta$ ។

a. ស្រាយថា $\frac{\sin A}{\sin B}=\frac{\sin\alpha}{\sin\beta}$

b. គណនាមុំ A, B, C ជាអនុគមន៍ α, β ។

០៥. ABCD ជាចតុកោណចារឹកក្នុងរង្វង់ ហើយ AB = a, BC = b, CD = c, DA = d ។

ស្រាយថា: $\tan\frac{A}{2}=\sqrt{\frac{(p-a)(p-d)}{(p-b)(p-c)}}$ ដែល $p=\frac{a+b+c+d}{2}$ ។

០៦. ស្រាយថាគ្រប់ ΔABC គេបាន: $(a-b)\cot\frac{C}{2}+(b-c)\cot\frac{A}{2}+(c-a)\cot\frac{B}{2}=0$ ។

០៧. ស្រាយបញ្ជាក់ថាបើមេដ្យាន AA’ និង BB’ នៃ ΔABC កែងគ្នា គេបាន:

$$\cot C=2(\cot A+\cot B)$$

២. បណ្តាលំហាត់ទាក់ទងវិសមភាព

០៨. ស្រាយបញ្ជាក់ថាគ្រប់ចតុកោណABCD គេបានវិសមភាព $AB + DC < AC + BD$ ។

០៩. ក្នុងចតុកោណប៉ោង ABCD មាន O ជាចំនុចប្រសព្វនៃអង្កត់ទ្រូង ហើយ S ជាក្រលាផ្ទៃ។

ស្រាយបញ្ជាក់ថា :

$OA^2 + OB^2 + OC^2 + OD^2 \geq 2S$ (សមភាពកើតឡើងនៅពេលណា) ។

១០. គេអោយ ΔABC មានក្រលាផ្ទៃស្មើ 1 និងរង្វាស់ជ្រុង a, b, c $(a \geq b \geq c)$ ។

ស្រាយបញ្ជាក់ថា $b \geq \sqrt{2}$ ។

១១. គេអោយ ΔABC មានក្រលាផ្ទៃ S ។ ចតុកោណកែង MNPQ ចារឹកក្នុង ΔABC ។

$M \in (AB), N \in (AC), P \& Q \in (BC)$ ។ តាង S' ជាក្រលាផ្ទៃ MNPQ ។

ស្រាយថា $S \geq 2S'$ ។

១២. ABCD ជាការេឯកតាមានជ្រុងស្មើ ១ ។ M ជាចំនុចមួយនៅលើជ្រុង [AD] & N ជាចំនុចមួយនៅលើជ្រុង [CD] ដែល $M\hat{B}N = 45^o$ ។ ស្រាយថា $\sqrt{2} - 1 \leq S_{MBN} \leq \frac{1}{2}$ ។

១៣. គេអោយចតុកោណ ABCD; O ជាចំនុចប្រសព្វអង្កត់ទ្រូង ។ តាង $S_1 = S_{AOB}$; $S_2 = S_{COD}$

$S = S_{ABCD}$ ។ ស្រាយថា $\sqrt{S_1} + \sqrt{S_2} \leq \sqrt{S}$ ។

១៤. គេអោយចតុកោណ ABCD មានក្រលាផ្ទៃ S ។ ស្រាយថា $S \leq \frac{1}{8}(AC+BD)^2$ ។

១៥. គេអោយ ΔABC មានមុំទាំងបីជាមុំស្រួច ។ H ជាអរតូសង់នៃ ΔABC ហើយ AM; BN; CL ជាកំពស់ ។ ស្រាយបញ្ជាក់ថា:

a. $\frac{HM}{AM}+\frac{HN}{BN}+\frac{HL}{CL}=1$

b. $\frac{AM}{HM}+\frac{BN}{HN}+\frac{CL}{HL}\geq 9$

c. $AM.HM\leq \frac{BC^2}{4}$

១៦. គេអោយ ΔABC & O ជាចំនុចមួយស្ថិតក្នុងត្រីកោណ ។ បន្ទាត់ OA; OB; OC កាត់ BC; CA; AB រៀងគ្នាត្រង់ P; Q; R ។ ស្រាយបញ្ជាក់ថា:

a. $\frac{OP}{AP}+\frac{OQ}{BQ}+\frac{OR}{CR}=1$

b. $\frac{AP}{OP}+\frac{BQ}{OQ}+\frac{CR}{OR}\geq 9$

១៧. គេអោយការេ QPSR ចារឹកក្នុង ΔABC កែងត្រង់ A ដែល P; R នៅលើជ្រុង AB & AC ហើយ Q & R នៅលើជ្រុង BC ។ ស្រាយបញ្ជាក់ថា $BC\geq 3QR$

តើសមភាពកើតនៅពេលណា ?

១៨. គេអោយចតុកោណប៉ោង ABCD ។ ស្រាយថា $AB.CD+AD.BC\geq AC.BD$ ។

១៩. គេអោយ ΔABC; O ជាចំនុចមួយនៅក្នុងត្រីកោណ ។ AO; BO; CO កាត់ BC; CA & AB ត្រង់ P; Q; R ។ ស្រាយថា $\sqrt{\frac{OA}{OP}}+\sqrt{\frac{OB}{OQ}}+\sqrt{\frac{OC}{OR}}\geq 3\sqrt{2}$ ។

២០. តាមចំនុច O នៅក្នុង ΔABC គូសបន្ទាត់បីស្របរៀងគ្នានឹងជ្រុង (AB); (BC); (CA) ដូចរូបខាងស្តាំ ។ ស្រាយបញ្ជាក់ថា $\frac{a}{\alpha}+\frac{b}{\beta}+\frac{c}{\delta}\geq\frac{3}{2}$ ។ បំរាប់ a; b; c ជាក្រលាផ្ទៃត្រីកោណ ហើយ α; β; δ ជាក្រលាផ្ទៃចតុកោណ ។



២១. គេអោយត្រីកោណ ABC មាន AM ជាមេដ្យាន ។

1. បើ $A<\frac{\pi}{2}$ ស្រាយថា:

a. $BC^2 < AB^2 + AC^2$

b. $BC < 2AM$

2. បើ $A>\frac{A}{2}$ ស្រាយថា:

a. $BC^2 > AB^2 + AC^2$

b. $BC > 2AM$

២២. គេអោយត្រីកោណ ABC កែងត្រង់ A ។ D ជាជើងកំពស់គូសចេញពី A ។ យក O_1; O_2 ជាផ្ចិតរង្វង់ចារឹកក្នុង ΔABD & ΔACD ។ បន្ទាត់កាត់តាម O_1; O_2 កាត់ (AB) & (AC) ត្រង់ E & F ។ ស្រាយបញ្ជាក់ថា $2S_{AEF}\leq S_{ABC}$ ។

២៣. គេអោយត្រីកោណ ABC មានមុំទាំងអស់ជាមុំស្រួច ។ H ជាអរតូសង់នៃត្រីកោណ និង a, b, c ជារង្វាស់ជ្រុង ។ ស្រាយថា $(AH+BH+CH)^2\leq a^2+b^2+c^2$ ។

២៤. គេអោយត្រីកោណ ABC ចារឹកក្នុងរង្វង់ផ្ចិត O ។ កន្លះបន្ទាត់ពុះក្នុងគូសចេញពី A កាត់ BC ត្រង់ A_1 និងរង្វង់ត្រង់ A_2 ។ ដូចគ្នាចំពោះកន្លះបន្ទាត់ពុះគូសចេញពី B & C កាត់ត្រង់ B_1; B_2; C_1; C_2 ។ ស្រាយថា $S=\frac{A_1A_2}{BA_2+A_2C}+\frac{B_1B_2}{AB_2+B_2C}+\frac{C_1C_2}{AC_2+C_2B}\geq\frac{3}{4}$ ។

២៥. គេអោយចតុកោណ ABCD មាន AB=a; CD=c; AD=BC; $A\hat{D}C+D\hat{C}B=90^o$ ។ M, N, P, Q ជាចំនុចកណ្តាលរៀងគ្នានៃ AB, AC, CD, BD ។ ស្រាយបញ្ជាក់ថា $S_{MNPQ}\geq\frac{(a-c)^2}{8}$ ។

២៦. គេអោយΔមានរង្វាស់ជ្រុង a; b; c & កន្លះបន្ទាត់ពុះក្នុងនៃមុំទាំងបីមានប្រវែង l_a; l_b; l_c ។ ស្រាយថា $\frac{1}{a}+\frac{1}{b}+\frac{1}{c}<\frac{1}{l_a}+\frac{1}{l_b}+\frac{1}{l_c}$ ។

២៧. គេអោយ ΔABC មាន A > B > C ។ O ជាចំនុចមួយនៅក្នុងត្រីកោណ ។ បណ្តាបន្ទាត់ (AO); (BO); (CO) កាត់ BC; CA; AB ត្រង់ P; Q; R ។ ស្រាយបញ្ជាក់ថា OP + OQ + OR < BC ។

២៨. គេអោយ ΔABC មាន O ឋិតនៅក្នុងត្រីកោណនោះ ។ បណ្តារបន្ទាត់ AO; BO; CO កាត់ BC; CA; AB ត្រង់ D; E; F ។ ស្រាយបញ្ជាក់ថា:

a. $\frac{OA}{AD}+\frac{OB}{BE}+\frac{OC}{CF}=2$

b. $\frac{OA}{OD}+\frac{OB}{OE}+\frac{OC}{OF}\geq 6$

២៩. គេអោយ ΔABC មានមុំ B ជាមុំទាល ។ នៅលើ (BC) គេដៅពីរចំនុច M; N ដែល BM=CN ។ ស្រាយថា AB + AC > AM + AN ។

៣០. ក្នុង ΔABC ដៅ A_1 លើ BC; B_1 លើ CA; C_1 លើ AB ។ ស្រាយបញ្ជាក់ថាយ៉ាងហោចណាស់មានមួយក្នុងចំនោម ΔAB_1C_1; ΔBC_1A_1; ΔCA_1B_1 មានក្រលាផ្ទៃតូចជាងរឺស្មើ $\frac{1}{4}$ នៃក្រលាផ្ទៃ ΔABC ។

៣១. ស្រាយបញ្ជាក់ថាគ្រប់ ΔABC គេបាន: $m_a.m_b.m_c \le \frac{27R^2}{8}$ ។

៣២. ស្រាយបញ្ជាក់ថា: $l_a r_a + l_b r_b + l_c r_c \le p^2$ ។

៣៣. គេអោយ P ជាចំនុចមួយនៅក្នុង ΔABC ។ ចំងាយពី P ទៅកំពូល A, B, C គឺ x, y, z និងចំងាយពី P ទៅ ជ្រុង AB, BC, CA គឺ p, q, r ។ ស្រាយបញ្ជាក់ថា:

a. $x+y+z \ge 2(p+q+r)$

b. $xyz \ge 8pqr$

៣៤. កំនត់តំលៃ p តូចបំផុតដែលគេអាចទាញបាន $S^2 \le p(a^4+b^4+c^4)$ ។

៣៥. គេអោយត្រីកោណ ABC មានក្រលាផ្ទៃ S និង m_a, m_b, m_c ជាមេដ្យានគូសចេញពីកំពូលទាំង ៣ ។ ស្រាយបញ្ជាក់ថា: $m_a^2+m_b^2+m_c^2 \ge 3\sqrt{3}S$ ។

៣៦. ស្រាយបញ្ជាក់ថា: $\frac{1}{r_a}+\frac{1}{r_b}+\frac{1}{r_c} \ge \sqrt[3]{\frac{4R^2}{r(a+b+c)abc}}$ ។

៣៧. គេអោយត្រីកោណ ABC មានក្រលាផ្ទៃ S និង មានប្រវែងជ្រុង a, b, c ។ ស្រាយបញ្ជាក់ថា: $a^2b^2+b^2c^2+c^2a^2 \ge 16S^2$ ។

៣៨. ស្រាយបញ្ជាក់ថា: $\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\ge 2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$ ។

៣៩. គេអោយត្រីកោណ ABC ដែលមាន $A\ge B\ge C$ ។ ស្រាយបញ្ជាក់ថា:

$$\frac{h_a}{h_b}+\frac{h_b}{h_c}+\frac{h_c}{h_a}\ge\frac{h_b}{h_a}+\frac{h_a}{h_c}+\frac{h_c}{h_b}$$

៤០. ស្រាយបញ្ជាក់ថា: $\frac{m_a}{h_a}+\frac{m_b}{h_b}+\frac{m_c}{h_c}\le\frac{R+r}{r}$ ។

៤១. ស្រាយបញ្ជាក់ថា: $(m_a^2+m_b^2+m_c^2)(h_a^2+h_b^2+h_c^2)\ge 27S^2$ ។

៤២. គេអោយ ΔABC មានមុំស្រួចបី ។ស្រាយបញ្ជាក់ថា:

ក. $h_a+h_b+h_c\ge 9r$

ខ. $\frac{1}{m_a}+\frac{1}{m_b}+\frac{1}{m_c}\ge\frac{2}{r}$

សញ្ញា (=) កើតមាននៅពេលណា ?

៤៣. គេអោយ ΔABC មានកំពូល C ។គេយក $\frac{AC}{AB}=k\ (k\ne 1)$ ។ គូសកន្លះបន្ទាត់ពុះ CM , AN និង BP ។ ស្រាយបញ្ជាក់ថា :

ក) $\frac{S_{ABC}}{S_{MNP}}=\left(\sqrt{k}+\frac{1}{\sqrt{k}}\right)^2$ ខ) $S_{MNP}<\frac{S_{ABC}}{4}$

៤៤. គេអោយΔABC មានទីប្រជុំទំងន់ G និង ចារឹកក្នុងរង្វង់ដែលមានកាំ R ។ បណ្តាមេដ្យានដែលគូសចេញពីកំពូល A , B , C កាត់ផ្ចូររង្វង់រៀងគ្នាត្រង់ D , E , F ។ ស្រាយបញ្ជាក់ថា: $\frac{3}{R}\le\frac{1}{GD}+\frac{1}{GE}+\frac{1}{GF}\le\sqrt{3}\left(\frac{1}{AB}+\frac{1}{AC}+\frac{1}{BC}\right)$ ។

៤៥. គេអោយΔABC, តាង D ជាចំនុចនៅលើជ្រុង BC ។ នៅលើបណ្តាជ្រុង AB និង AC គេដៅ ចំនុច P និង Q រៀងគ្នា ។ បណ្តាបន្ទាត់ដែលគូសចេញពី P និង Q ស្របនឹង AD ហើយកាត់ជ្រុង BC ត្រង់ N និង M ។ ស្រាយបញ្ជាក់ថា : $S_{MNPQ} \le \max\{S_{ABD}, S_{ACD}\}$ ។ សមភាពកើតមានឡើងនៅពេលណា ?

៣. បណ្តាលំហាត់ទាក់ទងតំលៃតូចនិងធំបំផុត

៤៦. គេអោយ ΔABC មានរង្វាស់ជ្រុង a, b, c និងបរិមាត្រ 10cm ។ គណនាក្រលាផ្ទៃធំបំផុតនៃ ΔABC រួចកំនត់ប្រភេទត្រីកោណដែលមានក្រលាផ្ទៃធំបំផុតនេះ ។

៤៧. គេអោយ ΔABC មានមុំបីជាមុំស្រួច ។ ពីចំនុច I មួយឋិតនៅក្នុង ΔABC គូស IH, IK, IL កែងនឹង BC, CA, & AB ។ រកទីតាំងចំនុច I ដែលធ្វើអោយ $AK^2 + BH^2 + CK^2$ តូចបំផុត ។

៤៨. គេអោយការេ ABCD មានរង្វាស់ជ្រុង a ។ H ជាចំនុចមួយនៅលើ [AC] ។ E & F ជាចំនោលកែងនៃ H លើ [AB] & [BC] ។ កំនត់ទីតាំង H ដើម្បីអោយ S_{DEF} មានតំលៃតូចបំផុត ។

៤៩. គេអោយត្រីកោណសម័ង្ស ABC; ចំនុច M & N នៅលើ [AB] & [AC] ដែល $\frac{AM}{MB} + \frac{AN}{NC} = 1$ ។ រកទីតាំងចំនុច M & N ដើម្បីអោយ S_{AMN} ធំបំផុត ។

៥០. គេអោយ ΔABC មាន $\angle A=30^o$, AB=c, AC=b, និង មេដ្យាន AM ។

គូសបន្ទាត់(d)មួយ កាត់តាមទីប្រជុំទំងន់ G នៃ ΔABC ហើយកាត់ AB ត្រង់ P និងកាត់ AC ត្រង់ Q ។

ក. ស្រាយបញ្ជាក់ថា: $\frac{AB}{AP}+\frac{AC}{AQ}=3$

ខ. តាង AP=x, រកតំលៃអតិបរមានិងតំលៃអប្បបរមានៃ x ។

៥១. គេអោយការេ ABCD មានប្រវែងជ្រុង a ។ តាង M,N,P ជាបីចំនុចរៀងគ្នានៅលើបណ្តាជ្រុង BC, CD, DA ដែល ΔMNP ជាត្រីកោណសម្ម័ង ។

ក) បងាញថា : $CN^2-AP^2 = 2\ DP.BM$ ។

ខ) កំនត់ទីតាំង M,N,P ដើម្បីអោយ ΔMNP មានក្រលាផ្ទៃតូចបំផុត ។

៤. បណ្តាលំហាត់ចំរុះ

៥២. នៅលើជ្រុង AC នៃ ΔABC ដៅចំនុច E ។ តាម E គូស (DE)//(BC) & (EF)//(AB) ។ ស្រាយថា $S_{BDEF} = 2\sqrt{S_{ADE}.S_{EFC}}$ ។

៥៣. តំបន់ ABCDEFGHIJ ផ្ទុកការេចំនួន 13 ប៉ុនៗគ្នា ហើយ តំបន់នេះចារឹកក្នុងចតុកោណកែង PQRS(មើលរូប).

គេអោយ PQ = 28 & QR = 26 ។

គណនាក្រលាផ្ទៃតំបន់នេះ ។



៥៤. ក្នុងរូបខាងស្តាំ ΔABC ជាត្រីកោណសមង្ស ហើយ P ជាចំនុច មួយក្នុងត្រីកោណ ។ បន្ទាត់កែង PR, PS & PT ត្រូវបានគូស ចេញពីចំនុច P ទៅកាន់ជ្រុងទាំងបីនៃត្រីកោណ ។ បង្ហាញថា ផលបូកក្រលាផ្ទៃឆ្នូតទាំងបីស្មើ $\frac{1}{2}$ នៃក្រលាផ្ទៃ ΔABC ។



៥៥. តាមចំនុច P ក្នុង ΔABC បន្ទាត់ AX, BY, CZ ត្រូវបាន គូសដូចបានបង្ហាញ ។ បង្ហាញថាបើត្រីកោណដែលមានផ្ទៃឆ្នូត ទាំងបីមានក្រលាផ្ទៃស្មើគ្នា នោះត្រីកោណតូចទាំង6មាន ក្រលាផ្ទៃស្មើគ្នា ។



៥៦. ក្នុងរូបខាងស្តាំ ABCD & AXYZ ជាប្រលេឡូក្រាម ដែល X នៅលើ [BC] និង D នៅលើ [YZ] ។ បង្ហាញថា ប្រលេឡូក្រាមទាំងពីរមានក្រលាផ្ទៃស្មើគ្នា ។



៥៧. ក្នុងរូបខាងស្តាំ បន្ទាត់ឈរមានប្រវែង 5cm កែងបន្ទាត់ដេកដែល មានប្រវែង$10\sqrt{3}$ cm ត្រង់ចំនុចកណ្តាល ហើយធ្នូកោងជាផ្នែកមួយ នៃរង្វង់ ។ គណនាក្រលាផ្ទៃដែលខណ្ឌដោយធ្នូកោង និង បន្ទាត់ដេក ។



៥៨. តាមចំនុចមួយក្នុង ΔABC គេគូសបន្ទាត់ចេញពីកំពូល ត្រីកោណកាត់តាមចំនុចនេះ ហើយចែក ΔABC ជា 6 ផ្នែក ។ បួនចំនែកមានក្រលាផ្ទៃ ដូចបានបង្ហាញ ។ គណនា S_{ABC} ។



៥៩. ΔABC មាន $AC = 7; BC = 24; \hat{C} = 90^{o}$ ។ M ជាចំនុចកណ្ដាល [AB]; D នៅតែម្ខាងនៃ(AB) ជាមួយ C និង DA = DB = 15 ។ រកក្រលាផ្ទៃ ΔCDM ។

៦០. គេអោយ ΔABC មានក្រលាផ្ទៃ 1 ឯកតា ។ X, Y, Z ជាចំនុចស្ថិតនៅលើអង្កត់ [AB], [BC], [AC] រៀងគ្នាដែល $\frac{AX}{AB} = \frac{BY}{CB} = \frac{CZ}{CA} = \frac{1}{3}$ ។ គណនាក្រលាផ្ទៃ ΔXYZ ។

៦១. ΔABC ជាត្រីកោណដែលគេអោយមុន ។ ប្រៀបធៀបក្រលាផ្ទៃឆកោណទាំងពីរ ។



៦២. [BC] ជាអង្កត់ផ្ចិតនៃរង្វង់ផ្ចិត O ។ A ជាចំនុចមួយនៅលើរង្វង់ដែលមុំ $A\hat{O}C > 60^{o}$ ។ [EF] ជាអង្កត់ធ្នូ និងជាមេដ្យាទ័រនៃ [AO] ។ D ជាចំនុចកណ្ដាលនៃធ្នូតូច AB ។ បន្ទាត់កាត់តាម O ហើយស្រប [AD] កាត់ [AC] ត្រង់ J ។ បង្ហាញថា J ជាផ្ចិតនៃរង្វង់ចារឹកក្នុង ΔCEF ។

៦៣. គេអោយប្រលេឡូក្រាម ABCD ដែលមានកំពូល A ជាមុំស្រួច ។ លើកន្លះបន្ទាត់ AB & CB តាងចំនុច H & K ដែល CH=CB & AK=AB ។ ស្រាយបញ្ជាក់ថាៈ

a. DH=DK

b. $\Delta DKH \cong \Delta ABK$ ។

៦៤. សង់ការេ BRSC & DCTU នៅលើជ្រុងពីរនៃប្រលេឡូក្រាម ABCD ។ ស្រាយថា AC=ST ហើយបន្លាយនៃ (AC) កែងនឹង (ST) ។

៦៥. គេអោយបន្ទាត់ (XY) និងរង្វង់ផ្ចិត O (បន្ទាត់មិនកាត់តាមរង្វង់ទេ) ។ ពីចំនុច A នៅលើ (XY) សង់បន្ទាត់ប៉ះរង្វង់ (AB) & (AC) ត្រង់ B & C ។

ស្រាយបញ្ជាក់ថា BC កាត់តាមចំនុចនឹងមួយកាលណា A រត់នៅលើ (XY) ។

៦៦. គេអោយ E; F; G ជាចំនុចនៅលើជ្រុង AB; AC; BC នៃ ΔABC ដែល AG; BF & CE កាត់គ្នាត្រង់ចំនុចមួយ ។ ស្រាយថា $\frac{AE}{EB}\cdot\frac{BG}{GC}\cdot\frac{CF}{FA}=1$ ។

៦៧. តាង P ជាចំនុចនៅលើរង្វង់ចារឹកក្រៅ ΔABC ។ $A_1; B_1; C_1$ ជាជើងចំនោលកែងគូសពី P ទៅលើជ្រុង AB; BC; CA ។ ស្រាយថា $A_1; B_1; C_1$ រត់ត្រង់គ្នា ។

៦៨. គេអោយចតុកោណកែង ABCD; M ជាចំនុចកណ្ដាល [AB]; N ជាចំនុចកណ្ដាល [CD]; Q នៅលើ [AC] ។ បន្ទាត់ (QM) កាត់បន្ទាត់ (BC) ត្រង់ P ។

ស្រាយបញ្ជាក់ថា $Q\hat{N}M = M\hat{N}P$ ។

៦៩. ក្នុងរូបខាងស្ដាំ បន្ទាត់ AB, CD & PQ ជាបន្ទាត់ប៉ះរួមទៅនឹងរង្វង់ទាំងពីរដែល A & C នៅលើរង្វង់តែមួយ ហើយ B & D នៅលើរង្វង់មួយទៀត ។ ចំនុច P & D នៅលើ AB & CD ។ ស្រាយថា PB = QC ។



៧០. បណ្ដាចំនុច P, Q, & R ត្រូវបានដៅនៅលើជ្រុង BC, AC , AB រៀងគ្នា នៃ ΔABC ដែល $BP=\frac{1}{3}BC,\ CQ=\frac{1}{3}CA,\ AR=\frac{1}{3}AB$ ។ បណ្ដាចំនុច X, Y ត្រូវបានដៅនៅលើអង្កត់ PR & QP ដែល $PX=\frac{1}{3}PR$ & $QX=\frac{1}{3}PQ$ ។ស្រាយថា (XY)//(BC) ។

៧១. គេអោយ ΔABC មានកំពូលត្រង់ A ។ តាង I ជាផ្ចិតរង្វង់ចារឹកក្រៅΔABC, D ជាចំនុចកណ្តាលជ្រុង AB , E ជាទីប្រជុំទំងន់នៃ ΔACD ។ ស្រាយបញ្ជាក់ថា : $IE \perp CD$ ។

៧២. គេអោយចតុកោណប៉ោង ABCD, នៅលើបណ្តាអង្កត់ AB, BC , CD , DA គេដៅបណ្តាចំនុច M ,N , P , Q ដែល AQ = DP = CN = BM ។ស្រាយបញ្ជាក់ថា បើ MNPQ ជាការេនោះ ABCDក៏ជាការេដែរ ។

៧៣. គេអោយចតុកោណ ABCD ចារឹកក្នុងរង្វង់ផ្ចិត(O), អង្កត់ទ្រូងទាំងពីរនៃចតុកោណកាត់គ្នាត្រង់M ។ ពីចំនុច P នៅលើជ្រុង AB គូសបន្ទាត់ PM , ពីចំនុច Q នៅលើជ្រុង BC គូសបន្ទាត់ QM ។ ស្រាយបញ្ជាក់ថាបើ $PM \perp CD$ នោះ $QM \perp AD$ ដែរ ។

៧៤. រង្វង់ (S) កាំ R ប៉ះនឹងបន្ទាត់ពីរស្របគ្នា (t_1) & (t_2) ។ រង្វង់ (S_1) កាំ r_1 ប៉ះនឹងរង្វង់ (S) និងបន្ទាត់ (t_1) ។ រង្វង់ (S_2) កាំ r_2 ប៉ះនឹងរង្វង់ (S) និងបន្ទាត់ (t_2) ហើយរង្វង់ (S_1) & (S_2) ជារង្វង់ប៉ះគ្នាផងដែរ ។ គណនា R ជាអនុគមន៍នៃ r_1 & r_2 ។

៧៥. ABCD ជាចតុកោណប៉ោងដែល AB = 8 ; BC = 6 ; BD = 10 ; $\hat{A} = \hat{D}$ & $A\hat{B}D = \hat{C}$ ។ គណនា CD ។

៧៦. ក្នុង ΔABC ; $B\hat{A}C = 100^\circ \& AB = AC$ ។ D ជាចំនុចមួយនៅលើ [AC] ដែល $A\hat{B}D = C\hat{B}D$ ។ បង្ហាញថា AB + DB = BC ។

៧៧. ក្នុង ΔABC ដៅចំនុច P មួយ ។ នៅលើជ្រុង AC & BC ដៅចំនុច M & L ដែល $P\hat{A}C = P\hat{B}C \& P\hat{L}C = P\hat{M}C = 90^\circ$ ។ ស្រាយបញ្ជាក់ថាបើ D ជាចំនុចកណ្តាល [AB] នោះ DM = DL ។

៧៨. ក្នុង ΔABC គេមាន $\hat{A}=30^o;\hat{B}=50^o;M\in(AC)$ ដែល $CM=CB$ ។ ស្រាយថា BM=AC ។

៧៩. ក្នុងត្រីកោណសមបាត ABC ដែលមានមុំកំពូល $\hat{C}=80^o$ ដៅចំនុច M ដែល $M\hat{B}A=30^o;M\hat{A}B=10^o$ ។ គណនា $A\hat{M}C$ ។

៨០. គេអោយចតុកោណព្នាយ ABCD មានបាត AB=a; CD=b & ជ្រុងទ្រេត AD=c; BC=d & អង្កត់ទ្រូង AC=p; BD=q ។ ស្រាយថា $p^2+q^2=c^2+d^2+2ab$ ។

៨១. D ជាចំនុចមួយនៅលើជ្រុង [AB] នៃ ΔABC ដែល AB=4AD ។ P ជាចំនុចមួយនៅលើរង្វង់ចារឹកក្រៅ ΔABC ដែល $A\hat{D}P=A\hat{C}B$ ។ បង្ហាញថា PB=2PD ។

៨២. គេអោយ ΔABC សម័ង្សចារឹកក្នុងរង្វង់ ។ P ជាចំនុចមួយនៅលើធ្នូ BC ។ ស្រាយថា $PA=PB+PC$ ។

៨៣. គេអោយការេ ABCD មួយ ។ ដៅចំនុច P ក្នុងការេដែល $P\hat{A}B=P\hat{B}A=15^o$ ។ ស្រាយថា PCD ជាត្រីកោណសម័ង្ស ។

៨៤. ក្នុងរូបខាងស្តាំ ABCD ជាបន្ទាត់ត្រង់ដែល AB=BC=CD=2 & AF=DE=2; BE=4 & FC=CE ។ គណនា FB ។



៨៥. គេអោយរង្វង់ផ្ចិត (O) កាំ r ប៉ះរង្វង់ (O’) កាំ R ។ បន្ទាត់ (L) ប៉ះរង្វង់ទាំងពីរត្រង់ S & T ។ គណនា |ST| ។

៨៦. គេកំនត់ |PQR| ជាក្រលាផ្ទៃនៃ PQR ។ បណ្តាអង្កត់ទ្រូងនៃ ABCD កាត់គ្នាត្រង់E ។ ឧបមាថា |AEB|=3; |DEC|=10; |BEC|=2|AED| ។ គណនា |AED| ។

៨៧. គេអោយ ΔABC ដូចរូបខាងក្រោម ។ដោយ (SR)//(CB);(TU)//(AC);(PQ)//(BC) ចូររកក្រលាផ្ទៃ ΔABC ដោយដឹងថាបន្ទាត់ (PQ); (TU); (SR) ចែក ΔABC ជាពីរ ចំនែកមានក្រលាផ្ទៃស្មើរគ្នា ហើយ $S_{XYZ}=1$ ។

៨៨. គេអោយ ABCD ជាចតុកោណប៉ោងមាន K; L; M; N ជាចំនុចកណ្តាលរៀងគ្នានៃ DC; DA; AB; BC ។ ឧបមាថា AK កាត់ BL; DN ត្រង់ P; S ហើយ CM កាត់ BL; DN ត្រង់ Q; R ។ គណនាក្រលាផ្ទៃនៃចទុកោណ PQRS ដោយដឹងថា $S_{ABCD}=3000$; $S_{AMQP}=513$ និង $S_{CKSR}=388$ ។

៨៩. គេអោយចតុកោណ ABCD មាន AD=$\sqrt{3}$; $A\hat{B}D = A\hat{C}D = 60^o$; E & F ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ ABD & ACD; បើ EF = $\dfrac{\sqrt{3}-1}{\sqrt{2}}$ ។ គណនា BC ។

៩០. នៅលើជ្រុងកែង [AC] & [BC] នៃ ΔABC សង់ខាងក្រៅនូវការេ ACKL & BCMN ។ (BL) កាត់ (AC) & (AN) រៀងគ្នាត្រង់ P & R ។ (AN) កាត់ (BC) ត្រង់ Q ។ ស្រាយថា $S_{CPRQ} = S_{ABR}$ ។

៩១. បន្ទាត់ (L) កាត់ជ្រុង [AB] & [AD] នៃប្រលេឡូក្រាម ABCD ត្រង់ E & F រៀងគ្នា ។ ឧបមាថា G ជាចំនុចប្រសព្វរវាង (L) & (AC) ។ ស្រាយថា $\dfrac{AC}{AG} = \dfrac{AB}{AE} + \dfrac{AD}{AF}$ ។

៩២. គេអោយរង្វង់ $(O_1; R_1)$; $(O_2; R_2)$ ប៉ះគ្នា ហើយរង្វង់ $(O_3; R_3)$ ប៉ះទៅនឹងរង្វង់ O_1; O_2 រួចប៉ះទៅនឹងបន្ទាត់ប៉ះក្រៅរវាង O_1 & O_2 ។ ស្រាយបញ្ជាក់ថា $\frac{1}{\sqrt{R_3}}=\frac{1}{\sqrt{R_1}}+\frac{1}{\sqrt{R_2}}$ ។

៩៣. ក្នុងបញ្ចកោណ ABCD មានរង្វាស់ជ្រុង 1; 2; 3; 4 & 5 ដោយមិនគិតពីលំដាប់ ។ គេយក F; G; H; I ជាចំនុចកណ្តាលរៀងគ្នានៃ AB; BC; CD; DE ។ X ជាចំនុចកណ្តាលនៃ [FH] & Y ជាចំនុចកណ្តាលនៃ [GI] ។ អង្កត់ [XY] មានតំលៃប្រវែងជាចំនួនគត់ ។ គណនាតំលៃដែលអាចមានរបស់ AE ។

៩៤. នៅលើជ្រុង BC នៃ ΔABC ដៅចំនុច P ដែល PC = 2BP ។ គណនា $A\hat{C}B$ បើ $A\hat{B}C=45^o; A\hat{P}C=60^o$ ។

៩៥. បណ្តាអង្កត់ទ្រូង AC & CE នៃឆកោណនិយ័ត ABCDEF ត្រូវចែកដោយចំនុច M & N ដែល $AM:AC=CN:CE=\lambda$ ។ គណនា λ បើ B, M, N រត់ត្រង់គ្នា ។

៩៦. រូបខាងស្តាំកើតឡើងពីត្រីកោណសមបាតប៉ុនគ្នាចំនួន 6 ដែលត្រូវបាន តំរៀបដោយមិនអោយជាន់គ្នា ។ ត្រីកោណនីមួយៗមានបាតប្រវែង 1ឯកតា និង ជ្រុងប្រវែង ២ឯកតា ។ គណនាប្រវែង AB ។



៩៧. នៅផ្ទៃកខាងក្នុងចតុកោណ ABCD ដៅ M ដែល ABMD ជាប្រលេឡូក្រាម ។ ស្រាយថា បើ $C\hat{D}M=C\hat{B}M$ នោះ $A\hat{C}D=B\hat{C}M$ ។

៩៨. ក្នុងរូបខាងស្តាំ រង្វង់ពីរប៉ះគ្នា ហើយចារឹកក្នុងកន្លះរង្វង់ដែល មានកាំ 2cm ។ បើរង្វង់ធំប៉ះអង្កត់ផ្ចិតនៃកន្លះរង្វង់ត្រង់ផ្ចិត C របស់វា គណនាកាំនៃរង្វង់តូច ។



៩៩. ក្នុងរូបខាងស្តាំ D ជាចំនុចកណ្តាលធ្នូ AC និង DE ⊥ AB ។
ស្រាយថា AE = EB + BC ។



១00. ΔABC កែងត្រង់ A មានប្រវែងបណ្តាជ្រុង BC=a , AB=c , CA=b ចារឹកក្នុងរង្វង់អង្កត់ ផ្ចិត BC ។ចំនុច P មួយនៅលើរង្វង់ដែល Pនិង A នៅសងខាង BC ។តាម P គូស PK ⊥ BC ត្រង់ K , PL ⊥ AC ត្រង់ L និង PM ⊥ AB ត្រង់ M ។តាងប្រវែងបណ្តាអង្កត់ PK, PL និង PM ជាលំដាប់រៀងគ្នា x ,y ,z ។

រកតំលៃអប្បបរមានៃផលបូក : $S = \frac{a}{x} + \frac{b}{y} + \frac{c}{z}$ ។

១0១. គេអោយចតុកោណប៉ោង ABCD ចារឹកក្នុងរង្វង់ផ្ចិត O ។ គេដឹងថាកន្លះបន្ទាត់ពុះនៃ បណ្តាមុំ BAD និង ABC កាត់គ្នាត្រង់ចំនុច E នៅលើជ្រុង CD ។

ក) បង្ហាញថា : AD + BC = CD ។

ខ) គេដឹងថា $\frac{CD}{CB} = k > 1$ ។ គណនា $\frac{S_{ADE}}{S_{BCE}}$ ។

១0២. គេអោយ ΔABC មានជ្រុង a; b; c & កំពស់ h_a; h_b; h_c ។ ស្រាយបញ្ជាក់ថាបើ

$$\frac{1}{h_a} + \frac{1}{h_b} + \frac{1}{h_c} = \frac{1}{\sqrt{p(p-a)}} + \frac{1}{\sqrt{p(p-b)}} + \frac{1}{\sqrt{p(p-oc)}}$$

នោះ ΔABC ជាត្រីកោណសម័ង្ស ។

១0៣. គេអោយ ΔABC មាន 0 < B < 90º ។ តាង AH; AD; AM ជាកំពស់ ជាកន្លះបន្ទាត់ពុះ និងជាមេដ្យានគូសចេញពី A ។ ស្រាយថា D នៅចន្លោះ M & H ។

១០៤. ក្នុង ΔABC គូសកំពស់ AD, BE & CF ។ ស្រាយថា $\frac{P'}{P}=\frac{r}{R}$ ដែល P' ជាបរិមាត្រ ΔEDF & P ជាបរិមាត្រ ΔABC ។

១០៥. ស្រាយបញ្ជាក់ថាបើត្រីកោណ ABC មានជ្រុងដែលផ្ទៀងផ្ទាត់:

$$2(a^3+b^3+c^3)=a(b^2+c^2)+b(c^2+a^2)+c(a^2+b^2)$$

នោះ ΔABC ជាត្រីកោណសម័ង្ស ។

១០៦. ស្រាយបញ្ជាក់ថាបើ $m_a+m_b+m_c=\frac{9R}{2}$ នោះ ΔABC ជាត្រីកោណសម័ង្ស ។

១០៧. ស្រាយថាគ្រប់ ΔABC គេបាន:

$$(a-b)\cot\frac{C}{2}+(b-c)\cot\frac{A}{2}+(c-a)\cot\frac{B}{2}=0 \text{ ។}$$

១០៨. កំនត់ប្រភេទត្រីកោណ ABC ដែលផ្ទៀងផ្ទាត់:

a. $S=\frac{1}{4}(a+b-c)(a-b+c)$

b. $S=\frac{\sqrt{3}}{36}(a+b+c)^2$

១០៩. ពីផ្ចិត O នៃរង្វង់ចារឹកក្រៅ ΔABC គូសបន្ទាត់កែង OA', OB' & OC' ទៅលើជ្រុង BC, CA & AB រៀងគ្នា(មុំ ΔABC ជាមុំស្រួច) ។ ស្រាយថា

$$OA'+OB'+OC'=R+r$$

១១០. P ជាចំនុចក្នុង ΔABC ។ PA កាត់ BC ត្រង់ D; PB កាត់ AC ត្រង់ E & PC កាត់ AB ត្រង់ F ។ បង្ហាញថាយ៉ាងហោចណាស់មានមួយក្នុងចំនោម $\frac{AP}{PD};\frac{BP}{PE};\frac{CP}{PF}$ មានតំលៃមិនលើសពី 2 និងយ៉ាងហោចណាស់មានមួយមានតំលៃធំជាង 2 ។

១១១. ក្នុងរង្វង់មួយដៅអង្កត់ធ្នូ AB និង ចំនុច C ដៅលើរង្វង់ដែល ចំងាយពី C ទៅ AB ស្មើ 4cm ។ បើ CA=6cm & CB=10cm គណនាអង្កត់ផ្ចិតនៃរង្វង់ ។

១១២. គេអោយចតុកោណប៉ោង ABCD ដែលអង្កត់ទ្រូង AC & BD កាត់គ្នាត្រង់ O ។ ឧបមាថា r_1, r_2, r_3, r_4 ជាកាំរង្វង់ចារឹកក្នុងនៃត្រីកោណ OAB, OBD, OCD & ODA រៀងគ្នា ហើយផ្ទៀងផ្ទាត់ $\frac{1}{r_1}+\frac{1}{r_3}=\frac{1}{r_2}+\frac{1}{r_4}$ ។ ស្រាយបញ្ជាក់ថា ABCD ជាចតុកោណចារឹកក្រៅរង្វង់ ។

១១៣. ក្នុង ΔABC គេអោយ D, E, F ជាចំនុចកណ្តាលនៃជ្រុង BC, CA, AB និង P, Q, R ជា ចំនុចកណ្តាលនៃមេដ្យាន AD, BE, CF រៀងគ្នា ។ ស្រាយថាតំលៃផលធៀប T ខាងក្រោម មិនអាស្រ័យនឹងរូបរាងរបស់ត្រីកោណ ហើយរកតំលៃនោះ ។

$$T=\frac{AQ^2+AR^2+BP^2+BR^2+CP^2+CQ^2}{AB^2+BC^2+CA^2}$$

១១៤. ក្នុង ΔPQR មាន PQ=8, QR=13 & PR=15 ។ បង្ហាញថាមានចំនុច S មួយនៅលើ PR (តែមិននៅចំនុចចុងនៃអង្កត់ទេ) ដែល PS & QS មានតំលៃគត់ ។

១១៥. គេអោយបញ្ចកោណនិយ័ត ABCDE ចារឹកក្នុងរង្វង់ (O) ។ នៅលើធ្នូ AB នៃ (O) ដៅចំនុច M (M មិនស្ថិតលើ A រឺ B ឡើយ) ។ ស្រាយបញ្ជាក់ថា:

$$MA + MB + MD = MC + ME$$

១១៦. គេអោយត្រីកោណ ABC មួយ ។ សង់ត្រីកាណ ABR, BCP, CAQ ដែលស្ថិតនៅជាប់ខាងក្រៅ ΔABC ហើយមាន $P\hat{B}C = C\hat{A}Q = 45^o, B\hat{C}P = Q\hat{C}A = 30^o$ និង $A\hat{B}R = B\hat{A}R = 15^o$ ។ ស្រាយថា $Q\hat{R}P = 90^o$ & $QR = RP$ ។

១១៧. គេអោយ a, b, c ជាជ្រុងនៃ ΔABC និង A ជាក្រលាផ្ទៃ ។ ស្រាយបញ្ជាក់ថា $a^2 + b^2 + c^2 \geq 4\sqrt{3}A$ ។ តើសមភាពកើតឡើងពេលណា ?

១១៨. កាំនៃរង្វង់ចារឹកក្រៅត្រីកោណសមបាតមួយមានប្រវែង R និង កាំរង្វង់ចារឹកក្នុងនៃត្រីកោណនេះគឺ r ។ បង្ហាញថាចំងាយរវាងផ្ចិតនៃរង្វង់ទាំងពីរគឺ $\sqrt{R(R-2r)}$ ។

១១៩. ត្រីកោណ ABC មានប្រវែងជ្រុង a, b, c ។ បន្ទាត់បីដែលប៉ះទៅនឹងរង្វង់ចារឹកក្នុងត្រូវបានគូសស្របទៅនឹងជ្រុងទាំងបី ។ បន្ទាត់ប៉ះនីមួយៗផ្គុំជាមួយ ជ្រុងពីរៗនៃត្រីកោណបង្កើតបានជាត្រីកោណដែលមានចំនួនសរុប3 ។ គណនាផលបូកសរុបរវាងក្រលាផ្ទៃរង្វង់ចារឹកក្នុងត្រីកោណទាំង3 និង រង្វង់ចារឹកក្នុង ΔABC ។

ជំពូក ៣

ដំណោះស្រាយ

០១. បង្ហាញថា $S=\frac{1}{4}(a^2\sin 2B+b^2\sin 2A)$

តាមទ្រឹស្តីបទ sin : $a=2R\sin A,\ b=2R\sin B$ គេបាន:

$$S=\frac{1}{4}(a^2\sin 2B+b^2\sin 2A)=R^2(\sin^2 A\sin 2B+\sin^2 B\sin 2A)$$

$$=2R^2\sin A\sin B(\sin A\cos B+\sin B\cos A)=2R^2\sin A\sin B\sin(A+B)$$

$$=2R^2\sin A\sin B\sin(180^\circ-C)=2R^2\sin A\sin B\sin C$$ ពិត

ដូចនេះ $S=\frac{1}{4}(a^2\sin 2B+b^2\sin 2A)$ ។

០២. ស្រាយថា $\cot A+\cot B+\cot C=\frac{R(a^2+b^2+c^2)}{abc}$

យើងមាន $\cot A=\frac{\cos A}{\sin A}=\frac{\frac{b^2+c^2-a^2}{2bc}}{\frac{a}{2R}}=\frac{R(b^2+c^2-a^2)}{abc}$

ដូចគ្នាដែរគេបាន $\cot B=\frac{R(a^2+c^2-b^2)}{abc}$, $\cot C=\frac{R(b^2+a^2-c^2)}{abc}$

ដូចនេះគេបាន $\cot A+\cot B+\cot C=\frac{R(a^2+b^2+c^2)}{abc}$ ។

០៣. ស្រាយថា $\cot\alpha=\frac{\sin(B-C)}{2\sin B\sin C}$

តាមទ្រឹស្តីបទ sin យើងបាន :

$$\frac{c}{\sin\alpha}=\frac{BM}{\sin B\hat{A}M}=\frac{a}{2\sin(B+\alpha)}$$

$$\Rightarrow \frac{\sin(B+\alpha)}{\sin\alpha}=\frac{a}{2c}=\frac{\sin A}{2\sin C}=\frac{\sin(B+C)}{2\sin C}$$

$$\Leftrightarrow \frac{\sin B\cos\alpha+\sin\alpha\cos B}{\sin\alpha}=\frac{\sin B\cos C+\sin C\cos B}{2\sin C}$$

$$\Leftrightarrow \sin B.\cot\alpha=\frac{\sin B\cos C+\sin C\cos B}{2\sin c}-\cos B$$



$$\Rightarrow \sin B\cot\alpha=\frac{\sin(B-C)}{2\sin C}$$

ដូចនេះ $\underline{\cot\alpha=\frac{\sin(B-C)}{2\sin B\sin C}}$ ។

០៤. *a.* <u>*ស្រាយថា*</u> $\frac{\sin A}{\sin B}=\frac{\sin\alpha}{\sin\beta}$

តាមទ្រឹស្តីបទ sin ក្នុង ΔACM & ΔBCM យើងបាន:

$$\frac{AM}{\sin\alpha}=\frac{CM}{\sin A}\ (1),\quad \frac{BM}{\sin\beta}=\frac{CM}{\sin B}(2)$$



ដោយ AM = BM

តាម (1) & (2) គេបាន $\underline{\frac{\sin\alpha}{\sin\beta}=\frac{\sin A}{\sin B}}$

b. <u>*គណនាមុំ A, B, C ជាអនុគមន៍*</u> α, β

បើ $\alpha=\beta$ នោះ $A=B=\frac{\pi}{2}-\alpha \,\&\, C=2\alpha$

បើ $\alpha\neq\beta$, ឧបមាថា $\alpha>\beta$ នោះ $\sin\alpha>\sin\beta$

តាម (a) : $\frac{\sin\alpha}{\sin\beta}=\frac{\sin A}{\sin B}\Leftrightarrow\frac{\sin\alpha}{\sin A}=\frac{\sin\beta}{\sin B}=\frac{\sin\alpha-\sin\beta}{\sin A-\sin B}=\frac{\sin\alpha+\sin b}{\sin A+\sin B}$

$$\Rightarrow \frac{\sin A-\sin B}{\sin A+\sin B}=\frac{\sin\alpha-\sin\beta}{\sin\alpha+\sin\beta}$$

$$\Leftrightarrow \tan\frac{A-B}{2}\cot\frac{A+B}{2}=\tan\frac{\alpha-\beta}{2}\cot\frac{\alpha+\beta}{2}$$

ដោយ $\alpha+\beta=C$ នោះ $\frac{A+B}{2}=\frac{\pi}{2}-\frac{\alpha+\beta}{2}\Rightarrow \cot\frac{A+B}{2}=\tan\frac{\alpha+\beta}{2}$

$$\Rightarrow \tan\frac{A-B}{2}\tan\frac{\alpha+\beta}{2}=\tan\frac{\alpha-\beta}{2}\cot\frac{\alpha+\beta}{2}$$

$$\Leftrightarrow \tan\frac{A-B}{2}=\tan\frac{\alpha-\beta}{2}\cot^2\frac{\alpha+\beta}{2}$$

តាង $\tan\frac{\varphi}{2}=\tan\frac{\alpha-\beta}{2}\cot^2\frac{\alpha+\beta}{2}$ នោះ $\tan\frac{A-B}{2}=\tan\frac{\varphi}{2}$

$$\Rightarrow \begin{cases}\frac{A-B}{2}=\frac{\varphi}{2}\\ \frac{A+B}{2}=\frac{\pi}{2}-\frac{\alpha+\beta}{2}\end{cases}\Rightarrow \begin{cases}A=\frac{\pi}{2}-\frac{\alpha+\beta}{2}+\frac{\varphi}{2}\\ B=\frac{\pi}{2}-\frac{\alpha+\beta}{2}-\frac{\varphi}{2}\end{cases}$$ ។

០៥. *ស្រាយថា:* $\tan\frac{A}{2}=\sqrt{\frac{(p-a)(p-d)}{(p-b)(p-c)}}$



យើងមាន $\tan^2\frac{A}{2}=\frac{\sin^2\frac{A}{2}}{\cos^2\frac{A}{2}}=\frac{1-\cos A}{1+\cos A}$

ដោយ $\hat{A}+\hat{C}=180^o\Rightarrow \cos A=-\cos C$

តាមទ្រឹស្តីបទកូស៊ីនីសក្នុង ΔABD & ΔCBD:

$$BD^2=a^2+d^2-2ad\cos A=b^2+c^2-2bc\cos C=b^2+c^2+2bc\cos A$$

$$\Rightarrow \cos A=\frac{a^2+d^2-b^2-c^2}{2(ad+bc)}$$

$$\bullet 1-\cos A=1-\frac{a^2+d^2-b^2-c^2}{2(ad+bc)}$$

$$=\frac{2ad-a^2-d^2+2bc+b^2+c^2}{2(ad+bc)}$$

$$=\frac{(b+c)^2-(a-d)^2}{2(ad+bc)}$$

$$=\frac{(b+c+d-a)(b+c+a-d)}{2(ad+bc)}$$

$$=\frac{2(p-a)(p-d)}{ad+bc}$$

$$\bullet 1+\cos A=1+\frac{a^2+d^2-b^2-c^2}{2(ad+bc)}=\frac{(a+d)^2-(b-c)^2}{2(ad+bc)}$$

$$=\frac{2(p-b)(p-c)}{ad+bc}$$

គេបាន $\tan^2\frac{A}{2}=\frac{1-\cos A}{1+\mathrm{co}A}=\frac{(p-a)(p-d)}{(p-b)(p-c)}$

ដូចនេះ $\underline{\tan\frac{A}{2}=\sqrt{\frac{(p-a)(p-d)}{(p-b)(p-c)}}}$ ។

០៦. *ស្រាយថា* $(a-b)\cot\frac{C}{2}+(b-c)\cot\frac{A}{2}+(c-a)\cot\frac{B}{2}=0$

យើងមាន $r=\frac{a\sin\frac{B}{2}\sin\frac{C}{2}}{\cos\frac{A}{2}}=\frac{a\sin\frac{B}{2}\sin\frac{C}{2}}{\sin\left(\frac{B}{2}+\frac{C}{2}\right)}=\frac{a\sin\frac{B}{2}\sin\frac{C}{2}}{\sin\frac{B}{2}\cos\frac{C}{2}+\sin\frac{C}{2}\cos\frac{B}{2}}$

$\Rightarrow\ a=r(\cot\frac{B}{2}+\cot\frac{C}{2})$

ដូចគ្នាដែរ គេបាន $b=r\left(\cot\frac{A}{2}+\cot\frac{C}{2}\right)$

$$c=r\left(\cot\frac{B}{2}+\cot\frac{A}{2}\right)$$

$$\bullet (a-b)=r\left(\cot\frac{B}{2}-\cot\frac{A}{2}\right)$$

$$\bullet (b-c)=r\left(\cot\frac{C}{2}-\cot\frac{B}{2}\right)$$

$$\bullet (c-a)=r\left(\cot\frac{A}{2}-\cot\frac{C}{2}\right)$$

គេបាន $\underline{(a-b)\cot\frac{C}{2}+(b-c)\cot\frac{A}{2}+(c-a)\cot\frac{B}{2}=0}$ ។

០៧. ស្រាយថា $\cot C=2(\cot A+\cot B)$

យក G ជាទីប្រជុំទំងន់នៃ ΔABC

គេបាន $AG^2=\left(\frac{2}{3}m_a\right)^2=\frac{4m_a^2}{9}$

$$=\frac{1}{9}(2b^2+2c^2-a^2)$$



ដូចគ្នាដែរ គេបាន $BG^2=\frac{1}{9}(2a^2+2c^2-b^2)$

ដោយ $AA' \perp BB' \Rightarrow AB^2=AG^2+BG^2$

$$\Leftrightarrow c^2=\frac{1}{9}(a^2+b^2+4c^2)$$

$$\Leftrightarrow a^2+b^2=5c^2$$

$$\Leftrightarrow a^2+b^2-c^2=4c^2$$

$$\Leftrightarrow 2ab\cos C=4c^2$$

តាមទ្រឹស្តីបទ sin គេបាន $a=2R\sin A,\ b=2R\sin B,\ c=2R\sin C$

$\Rightarrow 2.2R\sin A.2R\sin B.\cos C=4(2R\sin C)^2$

$\Leftrightarrow \sin A\sin B\cos C=2\sin^2 C \ \ (1)$

យើងពិនិត្យ $\cot C=2(\cot A+\cot B)\Leftrightarrow\frac{\cos C}{\sin C}=\frac{2\sin(A+B)}{\sin A\cos B}$

$$\Leftrightarrow \sin A \sin B \sin C = 2\sin^2 C \quad (2)$$

តាម (1) & (2) គេបាន $\underline{\cot C = 2(\cot A + \cot B)}$ ។

០៨. ស្រាយថា $AB + DC < AC + BD$

តាង O ជាអង្កត់ទ្រូងចតុកោណ ABCD



យើងមាន AC=OA+OC

BD=OB+OD

$\Rightarrow$ AC + BD = (OA+OB)+(OC+OD)

> AB + DC

ដូចនេះ $\underline{AB + DC < AC + BD}$ ។

០៩. ស្រាយបញ្ជាក់ថា: $OA^2 + OB^2 + OC^2 + OD^2 \geq 2S$



យើងមាន $S = S_1 + S_2 + S_3 + S_4$

$2S = 2S_1 + 2S_2 + 2S_3 + 2S_4$

$= \frac{1}{2}.2OA.OD\sin\alpha_1 + \frac{1}{2}.2\, OA.OB\sin\alpha_2$

$+ \frac{1}{2}.2\, OB.OC\sin\alpha_3 + \frac{1}{2}.2\, OC.OD\sin\alpha_4$

$= OA.OD\sin\alpha_1 + OA.OB\sin\alpha_2 + OB.OC\sin\alpha_3 + OC.OD\sin\alpha_4$

ដោយ $\sin\alpha_1 \leq 1;\ \sin\alpha_2 \leq 1;\ \sin\alpha_3 \leq 1;\ \sin\alpha_4 \leq 1$

$\Rightarrow OA.OD\sin\alpha_1 + OA.OB\sin\alpha_2 + OB.OC\sin\alpha_3 + OC.OD\sin\alpha_4$

$\leq OA.OD + OA.OB + OB.OC + OC.OD$

$\leq \dfrac{OA^2 + OD^2 + OA^2 + OB^2 + OB^2 + OC^2 + OC^2 + OD^2}{2}$

$= OA^2 + OB^2 + OC^2 + OD^2$

ដូចនេះ $\underline{2S \leq OA^2 + OB^2 + OC^2 + OD^2}$

សមភាពកើតឡើងកាលណា OA=OB=OC=OD; $\alpha_1=\alpha_2=\alpha_3=\alpha_4=90^o$ គឺ ABCD ជាការេ ។

១០. ស្រាយបញ្ជាក់ថា $b \geq \sqrt{2}$

យើងមាន $S=\frac{1}{2}bc\sin A \leq \frac{1}{2}bc$ $(\sin A \leq 1)$

ដោយ $b \geq c \Rightarrow \frac{1}{2}bc \leq \frac{1}{2}b^2$

$\Rightarrow S \leq \frac{1}{2}b^2$ ដូចនេះ $\underline{b \geq \sqrt{2}}$ ។

១១. ស្រាយថា $S \geq 2S'$

តាង H ជាកំពស់ ΔABC គូសចេញពីកំពូល A ។



យើងមាន $S=\frac{1}{2}\cdot AH\cdot BC;\ \ S'=MN\cdot NP$

ដោយ $(MN) // (BC) \Rightarrow \frac{AN}{AC}=\frac{MN}{BC}$ (1)

$(PN) // (AH) \Rightarrow \frac{CN}{CA}=\frac{PN}{AH}$ (2)

តាម (1) & (2) គេបាន $\frac{MN\cdot PN}{BC\cdot AH}=\frac{AN\cdot CN}{AC^2}$

$\Leftrightarrow \frac{S'}{2S}=\frac{AN\cdot CN}{AC^2}$

តាម Cauchy: $AN^2+CN^2 \geq 2\cdot AN\cdot CN \Rightarrow (AN+CN)^2 \geq 4AN\cdot CN$

$$\Leftrightarrow \frac{AC^2}{4} \geq AN\cdot CN$$

គេបាន $\frac{S'}{2S} \leq \frac{AC^2}{4AC^2} \Rightarrow \underline{S \geq 2S'}$ ។

១២. ស្រាយថា $\sqrt{2}-1 \le S_{MBN} \le \frac{1}{2}$

យើងមាន $S_{MBN} = \frac{1}{2}\cdot BM\cdot BN\sin 45^o = \frac{\sqrt{2}}{4}\cdot BM\cdot BN$

តាង $S = S_{MBN} = S_{ABC} - (S_1 + S_2 + S_3)$

$$=1-\left(\frac{1}{2}\cdot AM\cdot AB+\frac{1}{2}\cdot BC\cdot NC+\frac{1}{2}\cdot DM\cdot DN\right)$$

$$=1-\frac{1}{2}(AM+NC+DM\cdot DN)$$

$$=1-\frac{1}{2}\cdot[AM+NC+(1-AM).DN]$$

$$=1-\frac{1}{2}[AM-AM\cdot DN+NC+DN]$$

$$=1-\frac{1}{2}[AM(1-DN)+CD]$$



$$S=1-\frac{1}{2}[AM.CN+1]\Rightarrow AM.CN=1-2S$$

ម្យ៉ាងទៀត $S=\frac{\sqrt{2}}{4}\cdot BM\cdot BN=\frac{\sqrt{2}}{4}\sqrt{(1+AM^2)(1+CN^2)}$

$$=\frac{\sqrt{2}}{4}\sqrt{AM^2\cdot CN^2+AM^2+CN^2+1}$$

$$\Leftrightarrow\ S^2=\frac{1}{8}\left[(1-2S^2)+BM^2-1+BN^2-1+1\right]$$

$$\Leftrightarrow\ 8S^2=1-4S+4S^2+BM^2+BN^2-1$$

$$\Leftrightarrow\ 4S^2+4S=BM^2+BN^2\ge 2BM.BN=\frac{8}{\sqrt{2}}\cdot\frac{\sqrt{2}}{4}\cdot BM\cdot BN=\frac{8}{\sqrt{2}}S$$

$$\Leftrightarrow\ \sqrt{2}S^2+\sqrt{2}S-2S\ge 0$$

$$\Leftrightarrow\ S(\sqrt{2}S+\sqrt{2}-2)\ge 0$$ ដោយ $S>0$

$$\Rightarrow\ S+1-\sqrt{2}\ge 0\Leftrightarrow S\ge\sqrt{2}-1$$

ហើយ $S = 1 - \frac{1}{2}(AM.CN + 1)$

បើ M ត្រួតលើ A រឺ D $\Rightarrow AM.CN = 0 \Leftrightarrow S = 1 - \frac{1}{2} = \frac{1}{2}$

បើ M មិនត្រួតលើ A រឺ D $\Rightarrow AM.CN > 0 \Leftrightarrow S < 1 - \frac{1}{2} = \frac{1}{2}$

$\Rightarrow S \le \frac{1}{2}$

ដូចនេះ $\sqrt{2} - 1 \le S_{MBN} \le \frac{1}{2}$ ។

១៣. *ស្រាយថា* $\sqrt{S_1} + \sqrt{S_2} \le \sqrt{S}$



យើងមាន $S_1 = \frac{1}{2} \cdot OA \cdot OB \sin\alpha$

$S_2 = \frac{1}{2} \cdot OD \cdot OC \sin\alpha$

$S_1.S_2 = \frac{1}{2} \cdot OA \cdot OB \sin\alpha \times \frac{1}{2} \cdot OD \cdot OC \sin\alpha$

តែ $\alpha + \beta = 180^o \Rightarrow \sin\alpha = \sin\beta$

គេបាន $S_1.S_2 = \frac{1}{2} \cdot OA \cdot OB \sin\beta \times \frac{1}{2} \cdot OD \cdot OC \sin\beta$

នាំអោយ $S_1.S_2 = S_{OAD}.S_{OBC}$

ម្យ៉ាងទៀត $S = S_1 + S_2 + S_{OAD} + S_{OBC} \ge S_1 + S_2 + 2\sqrt{S_{OAD} \cdot S_{OBC}}$

$\Leftrightarrow S \ge S_1 + S_2 + 2\sqrt{S_1 \cdot S_2} = \left(\sqrt{S_1} + \sqrt{S_2}\right)^2$

ដូចនេះ $\sqrt{S} \ge \sqrt{S_1} + \sqrt{S_2}$ ។

១៤. ស្រាយថា $S \leq \frac{1}{8}(AC+BD)^2$



យើងមាន $S = S_{AOB} + S_{OBC} + S_{ODC} + S_{OAD}$

តែ $S_{AOB} = \frac{1}{2} OA \cdot OB \sin A\hat{O}B \leq \frac{1}{2}(OA.OB)$

ធ្វើដូចគ្នាដែរ គេបាន $S_{OBC} \leq \frac{1}{2}(OB.OC)$

$$S_{OCD} \leq \frac{1}{2}(OD.OC)$$

$$S_{OAD} \leq \frac{1}{2}(OA.OD)$$

$$\Rightarrow S \leq \frac{1}{2}(OB.OA + OB.OC + OC.OD + OD.OA)$$

$$\Leftrightarrow S \leq \frac{1}{2}\left[OB(AO+OC) + OD(OA+OC)\right]$$

$$\Leftrightarrow S \leq \frac{1}{2} AC.DB$$

តាម Cauchy $\Rightarrow AC^2 + DB^2 \geq 2AC.DB$

$$\Leftrightarrow \frac{(AC+DB)^2}{4} \geq AC.DB$$

នោះ $\underline{S \leq \frac{1}{8}(AC+DB)^2}$ ។

១៥. ស្រាយបញ្ជាក់ថា:

a. $\frac{HM}{AM} + \frac{HN}{BN} + \frac{HL}{CL} = 1$



យើងមាន $S_{ABC} = \frac{1}{2} AM.BC$

$$S_{HBC} = \frac{1}{2} HM.BC$$

$$\Rightarrow \frac{S_{HBC}}{S_{ABC}} = \frac{HM}{AM}$$

ដូចគ្នាដែរគេបាន $\frac{S_{HAC}}{S_{ABC}} = \frac{HN}{BN}; \ \frac{S_{HAB}}{S_{ABC}} = \frac{HL}{CL}$

នោះ $\frac{HM}{AM} + \frac{HN}{BN} + \frac{HL}{CL} = \frac{S_{HBC} + S_{HAC} + S_{HAB}}{S_{ABC}} = \frac{S_{ABC}}{S_{ABC}} = 1$

b. $\frac{AM}{HM} + \frac{BN}{HN} + \frac{CL}{HL} \geq 9$

តាមសំរាយខាងលើ $\Rightarrow \frac{AM}{HM} + \frac{BN}{HN} + \frac{CL}{HL} = S_{ABC}\left(\frac{1}{S_{HBC}} + \frac{1}{S_{HAC}} + \frac{1}{S_{AHB}}\right)$

$$= (S_{HBC} + S_{HAC} + S_{AHB})\left(\frac{1}{S_{HBC}} + \frac{1}{S_{HAC}} + \frac{1}{S_{AHB}}\right)$$

តាម Cauchy: $S_{HBC} + S_{HAC} + S_{AHB} \geq 3\sqrt[3]{S_{HBC} \cdot S_{HAC} \cdot S_{AHB}}$

$$\frac{1}{S_{HBC}} + \frac{1}{S_{HAC}} + \frac{1}{S_{AHB}} \geq 3\sqrt[3]{\frac{1}{S_{HBC} \cdot S_{HAC} \cdot S_{AHB}}}$$

$$\Rightarrow \frac{AM}{HM} + \frac{BN}{HN} + \frac{CL}{HL} \geq 9$$

c. $AM.HM \leq \frac{BC^2}{4}$

ΔABM & ΔHMC ជាត្រីកោណកែង $B\hat{A}M = L\hat{C}B$ (មុំជ្រុងកែងរៀងគ្នា)

$\Rightarrow \Delta ABM \sim \Delta HMC$ នោះ $\frac{AM}{BM} = \frac{MC}{HM} \Leftrightarrow AM.HM = BM.MC$

តាម Cauchy: $BM^2 + MC^2 \geq 2BM.MC$

$\Leftrightarrow \frac{(BM + MC)^2}{4} \geq BM.MC$ តែ BM+MC=BC

ដូចនេះ $AM.HM \le \dfrac{BC^2}{4}$ ។

១៦. ស្រាយបញ្ជាក់ថា:

a. $\dfrac{OP}{AP}+\dfrac{OQ}{BQ}+\dfrac{OR}{CR}=1$

តាង [AH] ជាកំពស់ ΔABC

H´ ជាចំនោលកែងពី $O \to AH$

$\Rightarrow$ [HH´] ជាកំពស់ ΔOBC



$$\left.\begin{aligned} S_{ABC} &= \frac{1}{2}AH.BC \\ S_{OBC} &= \frac{1}{2}HH'.BC \end{aligned}\right| \Rightarrow \frac{S_{OBC}}{S_{ABC}}=\frac{HH'}{AH}$$

ដោយ (OH´) // (BC) $\Rightarrow \dfrac{HH'}{AH}=\dfrac{OP}{AP}$

$$\Rightarrow \frac{S_{OBC}}{S_{ABC}}=\frac{OP}{AP}$$

ដូចគ្នាដែរគេបាន $\dfrac{S_{OAC}}{S_{ABC}}=\dfrac{OQ}{BQ};\ \dfrac{S_{OAB}}{S_{ABC}}=\dfrac{OR}{CR}$

គេបាន $\dfrac{OP}{AP}+\dfrac{OQ}{BQ}+\dfrac{OR}{CR}=\dfrac{S_{OBC}+S_{OAC}+S_{OAB}}{S_{ABC}}=1$

b. $\dfrac{AP}{OP}+\dfrac{BQ}{OQ}+\dfrac{CR}{OR}\ge 9$

$$\frac{AP}{OP}+\frac{BQ}{OQ}+\frac{CR}{OR}=S_{ABC}\left(\frac{1}{S_{OBC}}+\frac{1}{S_{OAC}}+\frac{1}{S_{OAB}}\right)$$

$$=\left(S_{OBC}+S_{OAC}+S_{OAB}\right)\left(\frac{1}{S_{OBC}}+\frac{1}{S_{OAC}}+\frac{1}{S_{OAB}}\right)\ge 9$$

១៧. *ស្រាយបញ្ជាក់ថា $BC \geq 3QR$*

យើងមាន:



$B\hat{P}Q = S\hat{C}B$ (មុំមានជ្រុងកែងរៀងគ្នា)

$\Rightarrow \Delta PBQ$ & ΔSCR ជាត្រីកោណកែងមាន:

$B\hat{P}Q = S\hat{C}B$ នោះ $\Delta PBQ \sim \Delta SCR$

វិបាក $\frac{BQ}{SR} = \frac{PQ}{RC} \Leftrightarrow SR.PD = BQ.RC \ (1)$

តែ $PQ = SR = QR \Rightarrow QR^2 = BQ.RC$

$BC = BQ + RC + QR \geq 2\sqrt{BQ.RC} + QR = 3QR$

សមភាពកើតឡើងកាលណា $BQ = RC$

តាម $(1) \Rightarrow BQ^2 = QR^2 \Rightarrow BQ = QP$ នោះ $A\hat{B}C = 45^o$

ដូចនេះ $BC \geq 3QR$ សមភាពកើតឡើងកាលណា ABC ជាត្រីកោណកែងសមបាត ។

១៨. *ស្រាយថា $AB.CD+AD.BC \geq AC.BD$*

តាង K ជាចំនុចមួយនៅក្នុងចតុកោណដែល



$A\hat{B}K = D\hat{B}C; B\hat{A}K = B\hat{D}C$

គេបាន $\Delta AKB \sim \Delta BCD$

វិបាក $\frac{AK}{DC} = \frac{BK}{CB} = \frac{AB}{BD}$

នោះ $AB.DC = BD.AK \ (1)$

ម្យ៉ាងទៀត $A\hat{B}D = A\hat{B}K + K\hat{B}D; K\hat{B}C = K\hat{B}D + D\hat{B}C$

នោះ $A\hat{B}D = K\hat{B}C$ តែ $\frac{AB}{BD} = \frac{BK}{CB} \Rightarrow \Delta ABD \sim \Delta BKC$

វិបាក $\frac{AB}{BK}=\frac{BD}{BC}=\frac{AD}{CK} \Rightarrow BC.AD=BD.CK \ (2)$

យក (1)+(2)$\Rightarrow$

$AB.DC+BC.AD=BD(AK+CK)\geq BD.AC$ $(AK+KC\geq AC)$

ដូចនេះ $\underline{AB.CD+AD.BC \geq AC.BD}$

សមភាពកើតឡើងកាលណា K លើ (AC) ។

១៩. *ស្រាយថា* $\sqrt{\frac{OA}{OP}}+\sqrt{\frac{OB}{OQ}}+\sqrt{\frac{OC}{OR}}\geq 3\sqrt{2}$



តាង $S_{OBC}=S_1; S_{OCA}=S_2; S_{OAB}=S_3; S_{ABC}=S$

$\Rightarrow S=S_1+S_2+S_3$

យើងមាន $\frac{S}{S_1}=\frac{S_1+S_2+S_3}{S_1}=1+\frac{S_2+S_3}{S_1}$ (1)

តែ $\frac{S}{S_1}=\frac{AP}{OP}=\frac{OA+OP}{OP}=1+\frac{OA}{OP}$ (2)

(1) & (2) គេបាន $\frac{OA}{OP}=\frac{S_2+S_3}{S_1}\Leftrightarrow\sqrt{\frac{OA}{OP}}=\frac{\sqrt{S_2+S_3}}{\sqrt{S_1}}$

ធ្វើដូចគ្នាដែរគេបាន $\sqrt{\frac{OB}{OQ}}=\frac{\sqrt{S_1+S_3}}{\sqrt{S_2}}$; $\sqrt{\frac{OC}{OR}}=\frac{\sqrt{S_1+S_2}}{\sqrt{S_3}}$

តាម Cauchy: $S_2+S_3\geq 2\sqrt{S_2S_3} \Rightarrow 2(S_2+S_3)\geq\left(\sqrt{S_2}+\sqrt{S_3}\right)^2$

$$\Leftrightarrow\sqrt{S_2+S_3}\geq\frac{\sqrt{S_2}+\sqrt{S_3}}{\sqrt{2}}$$

នាំអោយ $\sqrt{\frac{OA}{OP}}\geq\frac{\sqrt{S_2}+\sqrt{S_3}}{\sqrt{2}.\sqrt{S_1}}=\frac{1}{\sqrt{2}}\left(\frac{\sqrt{S_2}}{\sqrt{S_1}}+\frac{\sqrt{S_3}}{\sqrt{S_1}}\right)$

$$\sqrt{\frac{OA}{OP}}+\sqrt{\frac{OB}{OQ}}+\sqrt{\frac{OC}{OR}}\ge\frac{1}{\sqrt{2}}\left[\frac{\sqrt{S_2}}{\sqrt{S_1}}+\frac{\sqrt{S_3}}{\sqrt{S_1}}+\frac{\sqrt{S_1}}{\sqrt{S_2}}+\frac{\sqrt{S_2}}{\sqrt{S_2}}+\frac{\sqrt{S_1}}{\sqrt{S_3}}+\frac{\sqrt{S_2}}{\sqrt{S_3}}\right]\ge\frac{6}{\sqrt{2}}$$

ដូចនេះ $\sqrt{\frac{OA}{OP}}+\sqrt{\frac{OB}{OQ}}+\sqrt{\frac{OC}{OR}}\ge 3\sqrt{2}$ ។

២០. *ស្រាយបញ្ជាក់ថា* $\frac{a}{\alpha}+\frac{b}{\beta}+\frac{c}{\delta}\ge\frac{3}{2}$

តាម Cauchy: $\frac{a}{\alpha}+\frac{b}{\beta}+\frac{c}{\delta}\ge 3\sqrt[3]{\frac{abc}{\alpha\beta\delta}}$

ដោយ $a=\frac{1}{2}OE.OF\sin\alpha_2$

$b=\frac{1}{2}OG.OH\sin\alpha_3$

$c=\frac{1}{2}OJ.OI\sin\alpha_1$



$\Rightarrow abc=\frac{1}{8}OE.OF.OG.OH.OI.OJ$

$\times\sin\alpha_1\sin\alpha_2\sin\alpha_3$

ម្យ៉ាងទៀត $\alpha=OH.OI\sin\alpha_2$

$\beta=OJ.OE\sin\alpha_3$

$\delta=OF.OG\sin\alpha_1$

$\Rightarrow\alpha\beta\delta=OE.OF.OG.OH.OI.OJ.\sin\alpha_1\sin\alpha_2\sin\alpha_3$

នាំអោយ $\frac{abc}{\alpha\beta\delta}=\frac{1}{8}$ នោះ $\frac{a}{\alpha}+\frac{b}{\beta}+\frac{c}{\delta}\ge\frac{3}{2}$ ។

២១. សំរាយវិសមភាព

1.យើងមាន : $BC^2 = AB^2 + AC^2 - 2AB.AC\cos A$

បើ $A < \frac{\pi}{2} \Rightarrow \cos A > 0 \Rightarrow \underline{BC^2 < AB^2 + AC^2}$

ម្យ៉ាងទៀត : $4AM^2 = 2(AB^2 + AC^2) - BC^2 > 2BC^2 - BC^2$

$$\Rightarrow 4AM^2 > BC^2 \Rightarrow \underline{2AM > BC}$$

2.ស្រាយដូចសំនួរទី (1) ដែរ ។

២២. ស្រាយបញ្ជាក់ថា $2S_{AEF} \le S_{ABC}$



តាងរង្វង់ O_1 មានកាំ R_1

រង្វង់ O_2 មានកាំ R_2 និង $AD = h$

យើងមាន : $IO_2 = JO_2 - IJ$

តែ $JO_2 = AM = AH = AD - HD$

$= AD - O_2P = h - R_2$

$IJ = O_1L = R_1$

នោះ $IO_2 = h - R_1 - R_2$

ធ្វើដូចគ្នាដែរចំពោះ $IO_1 = h - R_1 - R_2$

ដូចនេះ $IO_1 = IO_2$ ។

$\Delta \perp IO_1O_2$ មាន $IO_1 = IO_2$ នោះ ΔIO_1O_2 ជាត្រីកោណកែងសមបាត ។

តែ $O_1\hat{O}_2I = O_2\hat{F}A = 45^o$ ហើយ $F\hat{M}O_2 = 90^o$

នាំអោយ ΔMO_2F ជាត្រីកោណកែងសមបាត ។

វិបាក $O_2M = MF = R_2$

$AF = AM + MF = AH + MF = h - R_2 + R_2 = h$

Δ AEF ជាត្រីកោណកែងមាន $A\hat{F}E = 45^o \Rightarrow AE = AF = h$

$S_{AEF} = \frac{1}{2}h^2$

$S_{ABC} = \frac{1}{2}h.BC$

$\Rightarrow \frac{S_{AEF}}{S_{ABC}} = \frac{h}{BC} = \frac{BC.h}{BC^2} = \frac{AB.AC}{AB^2 + AC^2} \leq \frac{1}{2}$

ដូចនេះ $\underline{2S_{AEF} \leq S_{ABC}}$ ។

២៣. *ស្រាយថា* $(AH+BH+CH)^2 \leq a^2 + b^2 + c^2$

ដោយ $\angle BAA_1$ ជាមុំរួមរវាង $\Delta \perp AHC_1$ & $\Delta \perp AA_1B$

$\Rightarrow \Delta AHC_1 \sim \Delta AA_1B$



វិបាក $\frac{AC_1}{AA_1} = \frac{AH}{AB} \Leftrightarrow AH.AA_1 = AC_1.AB$

ក្នុង $\Delta AC_1C: \cos A = \frac{AC_1}{AC} \Rightarrow AC_1 = \cos A.AC$

នោះ $AH.AA_1 = AB.AC\cos A = \frac{b^2 + c^2 - a^2}{2}$

ធ្វើដូចគ្នាដែរ $\Rightarrow CH.CC_1 = \frac{a^2 + b^2 - c^2}{2}$; $BH.BB_1 = \frac{a^2 + c^2 - b^2}{2}$

នាំអោយ $AH.AA_1 + BH.BB_1 + CH.CC_1 = \frac{a^2 + b^2 + c^2}{2}$

ម្យ៉ាងទៀត តាមលំហាត់លេខ ១៩.a : $\frac{HA_1}{AA_1} + \frac{HB_1}{BB_1} + \frac{HC_1}{CC_1} = 1$

$\Leftrightarrow \frac{AA_1 - AH}{AA_1} + \frac{BB_1 - BH}{BB_1} + \frac{CC_1 - CH}{CC_1} = 1 \Rightarrow \frac{AH}{AA_1} + \frac{BH}{BB_1} + \frac{CH}{CC_1} = 2$

តាមវិសមភាព Buniakovsky :

$$\left(\frac{\sqrt{AH}}{\sqrt{AA_1}}\sqrt{AH}.\sqrt{AA_1}+\frac{\sqrt{BH}}{\sqrt{BB_1}}\sqrt{BH}\sqrt{BB_1}+\frac{\sqrt{CH}}{\sqrt{CC_1}}\sqrt{CH}.\sqrt{CC_1}\right)^2$$

$$\le\left(\frac{AH}{AA_1}+\frac{BH}{BB_1}+\frac{CH}{CC_1}\right)(AH.AA_1+BH.BB_1+CH.CC_1)$$

$$\Leftrightarrow\ (AH+BH+CH)^2\le 2\frac{a^2+b^2+c^2}{2}$$

$$\Rightarrow\ (AH+BH+CH)^2\le a^2+b^2+c^2$$

ដូចនេះ $\underline{(AH+BH+CH)^2\le a^2+b^2+c^2}$ ។

២៤. *ស្រាយថា* $S=\frac{A_1A_2}{BA_2+A_2C}+\frac{B_1B_2}{AB_2+B_2C}+\frac{C_1C_2}{AC_2+C_2B}\ge\frac{3}{4}$

យើងមាន : $[AA_2)$ ជាកន្លះបន្ទាត់ពុះមុំ A $\Rightarrow A_2B=A_2C$

តែ $AA_2.BC=AB.A_2C+BA_2.AC$

នាំអោយ $AA_2.BC=A_2C(AB+AC)$

$$\Leftrightarrow\ \frac{BC}{AB+AC}=\frac{A_2C}{AA_2}$$


